**TKI0765**

# សម្ភាសន៍ជាមួយឈ្មោះ ហាយ យឹម ភេទស្រី អាយុ៥៤ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ នារីពេទ្យ

ស្រុកកំណើតនៅភូមិត្រពាំងរុន ឃុំរាមអណ្តើក ស្រុកគីរីវង់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិធំ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៤៧:១៩

២៦ទំព័រ

វណ្ណៈ : បាទ! ចឹងថ្ងៃហ្នឹង ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០ ។ មុននឹងធ្វើការសម្ភាស ខ្ញុំសូមណែនាំខ្លួនខ្ញុំ ថាខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាណាមីងណា៎ ។

យឹម : ចា៎!

វណ្ណៈ : ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ។ ហើយចាំខ្ញុំទុកលេខទូរស័ព្ទ ហើយក្នុងនេះក៏មានលេខទូរស័ព្ទដែរណា សៀវភៅណាមីងណា ។ ហើយចឹងខ្ញុំចង់សម្ភាសមីងទាក់ទងនឹងរឿង ពេលដែលមីងធ្លាប់ឆ្លងកាត់ ប្រវត្តិមីងពីតូចៗបានរៀននៅណា? កើតជាអីនៅណាអីហ្នឹងណាមីងណា៎!

យឹម : ចា៎!

វណ្ណៈ : ហើយខ្ញុំចង់ដឹងប្រវត្តិខ្លះៗ ដើម្បីប្រវត្តិរបស់មីងហ្នឹង ចង់ឲ្យក្មេងៗជំនាន់ក្រោយបានសិក្សាបានរៀនសូត្របានអី ឲ្យបានដឹងថាយើងនៅក្នុងសម័យហ្នឹង វាកើតមានរឿងរ៉ាវចឹងមែន ព្រោះអីពីប្រវត្តិសាស្ត្រមកយើងមិនអាចចោល ដូចជំនាន់បារាំងកាន់កាប់យើងជំនាន់ជប៉ុនកាន់កាប់យើង ក៏យើងត្រូវតែសរសេរឲ្យដឹងដែរ ។

យឹម : ចា៎!

វណ្ណៈ : ចឹងរបបមួយៗ តែងតែមានកត់ជា កត់ត្រាជាប្រវត្តិសាស្ត្រណាមីងណា៎!

យឹម : ចា៎!

វណ្ណៈ : ទៅចឹង ខ្ញុំចង់សម្ភាសមីង តើបទសម្ភាសរបស់ខ្ញុំហ្នឹងអាចយកទៅប្រើប្រាស់ដូចជាសរសេរសៀវភៅ សរសេរអីបានទេមីង ឲ្យក្មេងៗបានដឹងបានទេ? មីងអនុញ្ញាតទេ?

យឹម : មានអី! ចុះបើអូនឯង សួរម៉េចខ្ញុំឆ្លើយចឹងទៅអាច...

វណ្ណៈ : បាទ ប៉ុន្តែបទសម្ភាសរបស់ខ្ញុំនេះ អាចសរសេរអាចអីបានណាមីងណា?

យីម : ហ្នឹងហើយ តាមខ្ញុំដឹងខ្ញុំធ្វើចឹងទៅ។

វណ្ណៈ : បាទៗ! ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីងដែរ មីងឈ្មោះអី?

យីម : ខ្ញុំឈ្មោះ ហាយ យីម។

វណ្ណៈ : ហាយ?

យីម : ហាយ យីម។

វណ្ណៈ : ហាយ យីម?

យីម : ចាំ!

វណ្ណៈ : មីងមានឈ្មោះហៅក្រៅទេ?

យីម : អត់មានក្រៅទេ ឈ្មោះចឹងហ្នឹង។

វណ្ណៈ : បាទ! សព្វថ្ងៃ មីងអាយុប៉ុន្មានហើយ?

យីម : អាយុ ៥៤អូន។

វណ្ណៈ : អាយុ ៥៤ឆ្នាំ។ គ្រួសារមីងឈ្មោះអី?

យីម : ឈ្មោះ សូ ចៀន។

វណ្ណៈ : សូ?

យីម : សូ ចៀន។

វណ្ណៈ : ចៀនហ៎?

យីម : ចាំ!

វណ្ណៈ : គាត់អាយុប្រហែលប៉ុន្មានហើយគាត់?

យីម : គាត់ ៥៦។

វណ្ណៈ : ៥៦ឆ្នាំ។ មីងសព្វថ្ងៃមានកូនចៅប៉ុន្មាននាក់?

យីម : កូន៦នាក់។

វណ្ណៈ : កូន៦នាក់។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យីម : ស្រី២ ប្រុស៤។

វណ្ណៈ : អឺ! ចឹងកំណើតកើតជារបស់មីងហ្នឹង នៅភូមិអី?

យីម : នៅត្រពាំងរុនហ្នឹង។

វណ្ណៈ : នៅ?

យីម ៖ ត្រពាំងវុន ។

វណ្ណៈ ៖ នៅត្រពាំងវុន ឃុំ?

យីម ៖ ឃុំ រាមអណ្ដើក ។

វណ្ណៈ ៖ ស្រុកត្រាំកក់?

យីម ៖ គិរីវង់ ។

វណ្ណៈ ៖ ស្រុកគិរីវង់ណា?

យីម ៖ ចា៎! កើតក្នុងហ្នឹង ។

វណ្ណៈ ៖ បាទ! ចឹងសព្វថ្ងៃមីងនៅអី សព្វថ្ងៃ?

យីម ៖ នៅអី?

វណ្ណៈ ៖ សព្វថ្ងៃនៅភូមិអី?

យីម ៖ នៅហ្នឹង ភូមិធំហ្នឹង ។

វណ្ណៈ ៖ នៅភូមិធំ ឃុំ?

យីម ៖ ឃុំកំពែង ។

វណ្ណៈ ៖ នៅភូមិធំ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ ។

យីម ៖ ចា៎!

វណ្ណៈ ៖ មីង! មីងមានបងប្អូនបង្កើតរបស់មីង ប៉ុន្មាននាក់ដែរ?

យីម ៖ បងប្អូនបង្កើតខ្ញុំតែ ៣នាក់ ។

វណ្ណៈ ៖ ៣នាក់?

យីម ៖ ស្លាប់អស់ហើយ នៅម្នាក់ឯង ។

វណ្ណៈ ៖ ៣នាក់?

យីម ៖ ៣នាក់ ។

វណ្ណៈ ៖ ស្លាប់ពីរ?

យីម ៖ ស្លាប់២ ។

វណ្ណៈ ៖ ស្លាប់ដោយសារមូលហេតុអីដែរ?

យីម ៖ ស្លាប់មួយ គ្រុនចាញ់ មួយវាជម្ងឺថ្លើម ។

វណ្ណៈ ៖ ស្លាប់ជំនាន់ផលូវ?

យីម ៖ ស្លាប់ផលូវ ។

វណ្ណៈ : ឥលូវទេ។ ចុះឪពុកមីងឈ្មោះអី ឪពុក?

យឹម : ឪពុកឈ្មោះ ហាយ នន។

វណ្ណៈ : ហាយ នន ហ៎?

យឹម : ចា៎!

វណ្ណៈ : ម្ដាយ?

យឹម : ម្ដាយឈ្មោះ សុខ កាន ប្រពន្ធគាត់ ម្ដាយខ្ញុំ។

វណ្ណៈ : បាទ! គាត់រាល់ថ្ងៃ គាត់នៅដែរ?

យឹម : ស្លាប់អស់ហើយ។

វណ្ណៈ : ស្លាប់។

យឹម : ស្លាប់យូរហើយ ស្លាប់ ម្ដាយខ្ញុំ តែ៣០ឆ្នាំ គាត់ស្លាប់។

វណ្ណៈ : ស្លាប់ជំនាន់ ប៉ុលពត ក៏ស្លាប់ឥលូវ?

យឹម : ជំនាន់តាំងពីដើមនោះ។

វណ្ណៈ : តាំងពីដើម?

យឹម : ជំនាន់តាំងពីខ្ញុំមកនៅ មិនទាន់ដឹងអីនោះ។

វណ្ណៈ : អូ! គាត់ឈឺអីទៅ?

យឹម : គាត់កូនង៉ែតខ្ចី មួយប្អូនខ្ញុំមីពៅហ្នឹង ដល់នេះគ្មានពេទ្យគ្មានអីគេថាក្រឡាភ្លើង។

វណ្ណៈ : អូ! កាលហ្នឹងដោយសារអត់ អត់សូវមានពេទ្យជំនាញណា។

យឹម : ចា៎! អត់មានពេទ្យ មានអី។ ស្លាប់យូរហើយ តាំងខ្ញុំមិនទាន់ដឹងមិនទាន់ឃើញមុខម៉ែម៉េច
ផង ពួកខ្ញុំ៣នាក់ហ្នឹង។

វណ្ណៈ : អូ ទើបមាន៣?

យឹម : ចា៎ ៣! តូចៗមិនទាន់ដឹងផងហ្នឹង មិនដឹងមុខម៉ែម៉េចផង។

វណ្ណៈ : មីងកូនពៅ កូនបង?

យឹម : ខ្ញុំកូនច្បង ៣នាក់ហ្នឹងខ្ញុំបងគេ ហើយដល់ឥលូវប្អូនៗស្លាប់អស់ហើយ។

វណ្ណៈ : ហ្អឹក! មីងកូនបង?

យឹម : កូនបង ហើយប្អូន២ហ្នឹងស្លាប់អស់ហើយ ពពោះហើយតែ៣នាក់។

វណ្ណៈ : បាទ ហើយកើតប្អូនក្រោយ ទើបគាត់ស្លាប់?

យឹម : ចា៎!

វណ្ណៈ : ហើយឪពុកទើបស្លាប់?

យឹម : ឪពុកទើបស្លាប់ គាត់អាយុ៧២ដែរហើយ ៤-៥ កាលបោះឆ្នោតនេះ លើកមុននេះ ។

វណ្ណៈ : អូ! ចឹងទេ?

យឹម : ចា៎! ស្លាប់ជំនាន់ហ្នឹង ។

វណ្ណៈ : បាទ ចុះមីងកាលពីតូចអី មីងបានរៀនដល់ថ្នាក់ណា?

យឹម : រៀនដល់ថ្នាក់ទី១០ ជំនាន់មុនហ្នឹង ថ្នាក់ទី១០ចាស់ ។

វណ្ណៈ : ទី១០ចាស់ ។ រៀននៅសាលាណា?

យឹម : នៅសាលាវត្តពោធិអុង ។

វណ្ណៈ : សាលា?

យឹម : ពោធិអុង ។

វណ្ណៈ : វត្តពោធិអុងហ៎?

យឹម : ចា៎! ពោធិអុង ។

វណ្ណៈ : សាលាវត្តពោធិអុង ។ ចុះមីងហេតុបានមីងរៀនបានត្រឹមតែថ្នាក់ទី១០ មីងមិនរៀនតទៀត?

យឹម : រៀនទៅ ឪក៏មិនសូវ ដល់ម៉ែស្លាប់ទៅ គាត់មិនសូវយកចិត្តទុកដាក់ រៀនបានប៉ុណ្ណឹងមិនបានជ្រៅជ្រះទៅមុខទៀតអី ។

វណ្ណៈ : ដោយសារ ។

យឹម : ដោយសារម៉ែស្លាប់ គាត់មិនសូវដឹងកូនដឹងអីទៅចឹងទៅ ក៏ឈប់ទៅ ។

វណ្ណៈ : មកជួយធ្វើការងារឪពុកហ្នឹង?

យឹម : ចា៎! នៅប្អូន២ ។

វណ្ណៈ : ជួយធ្វើស្រែ ក៏ធ្វើអី?

យឹម : ធ្វើស្រែ ។

វណ្ណៈ : ចឹងអី! ដោយសារថាអី ឪពុកអីគាត់អត់ទាន់មានគ្រួសារគេទៀត ហើយមានបងប្អូនក៏...

យឹម : ចា៎! កាលហ្នឹងអត់ទាន់មានទេ នៅតែខ្ញុំ ហើយប្អូនហើយនឹងពោះមួយ៣នាក់ហ្នឹង ។

វណ្ណៈ : ៣ហ្នឹងស្រីទាំងអស់ ឬ?

យឹម : ស្រី២ ប្រុស១ ។ ប្រុសទើបស្លាប់ ២-៣ឆ្នាំដែរហ្នឹង ។

វណ្ណៈ : អូ!

យឹម : គ្នាកើតជម្ងឺថ្មើម ។

វណ្ណៈ : បាទ! ចុះមីង ជំនាន់ហ្នឹងមីងមានជម្រៀសអីទៅណាអីទេ?

យឹម : ជម្រៀសកាលឡើងទៅហ្នឹង កាលឡើងពី...

វណ្ណៈ : កាលដូចថា មើល៎ជំនាន់សីហនុឆ្នាំ ជំនាន់សីហនុមីងនៅ កើតទាន់ទេកាលហ្នឹង?

យឹម : ជំនាន់សីហនុ ចុះឥលូវអាយុ៥០អីដែរហើយ ជំនាន់សីហនុនៅក្មេងៗចឹងទៅ ។

វណ្ណៈ : បាទ!

យឹម : នៅរៀនជំនាន់សីហនុហ្នឹង ។

វណ្ណៈ : បាទៗ! ចុះជំនាន់៧០ ៧០រដ្ឋប្រហារហើយ?

យឹម : រដ្ឋប្រហារឆ្នាំ៧០ហ៎?

វណ្ណៈ : បាទ!

យឹម : ៧០ហ្នឹងនៅផ្ទះដែរ ។

វណ្ណៈ : នៅផ្ទះទេណ៎?

យឹម : នៅផ្ទះ នៅតូចៗមិនទាន់ធំទេ ដល់ជំនាន់អាពត បានអាយុ២២ ។

វណ្ណៈ : បាទ!

យឹម : ម្ដាជាងហ្នឹងមក បានថាធ្វើកងចល័តកងអី ដល់យូរណោះបានធ្វើពេទ្យធ្វើអី គេឲ្យនៅព្យាបាលហ្នឹងទៅហ្នឹងណា ។

វណ្ណៈ : បាទ! ចុះមីងដំបូង ចឹងដល់ពេលដែលខ្មែរក្រហមចូលមកឆ្នាំ៧៥ ថ្ងៃ១៧ ឆ្នាំ៧៥ ១៩៧៥ហ្នឹង ថ្ងៃ១៧ មេសាហ្នឹង ខ្មែរក្រហមចូលទូទាំងប្រទេសហើយណ៎ ។

យឹម : ខ្មែរក្រហមឈ្នះហ្នឹង ក៏នៅផ្ទះដែរ មានទាន់គេរើសអីទៅណាផងហ្នឹង?

វណ្ណៈ : ចឹងដល់ថ្ងៃណា ឆ្នាំណា មីងទៅធ្វើកងចល័ត?

យឹម : មិនបានដឹង! គាកងចល័តគេរើសហ្នឹង មិនដឹងឆ្នាំណាម៉ានទៀត តូចៗភ្លេចអស់មិនដឹងកាលធ្វើពេទ្យក៏មិនឆ្នាំម៉ានទៀតណា ។ វាធ្វើបាននេះ ប៉ុន្មានឆ្នាំទេ វា...

វណ្ណៈ : ចុះមីង ដូចថា ឧបមាថាខ្មែរក្រហមចូលមក ប៉ុន្មានខែបានមីងទៅ?

យឹម : ធ្វើយូរ យូរបានគេរើសគេអី ។

វណ្ណៈ : មានបាយរួមបាយអី?

យឹម : មានបាយរួម រួមទៅធ្វើកងអី បានគេរើសចេញជា ។

វណ្ណៈ : ចឹងប្រហែលជាចុងឆ្នាំ ។

យឹម ៖ បើដាក់ព្រាវគ្មានដឹងឆ្នាំទេអូន ។

វណ្ណៈ ៖ ជាចុងឆ្នាំ៧៥ មីងធ្វើកងចល័តណា? នារីកងចល័ត?

យឹម ៖ អឹវា អាយុកាលហ្នឹងវាជាង១០ឆ្នាំហើយ ជិត២០ដែរហើយ ទៅកងចល័តហ្នឹង ។

វណ្ណៈ ៖ កុមារកងចល័ត កងចល័តនារីទេអី?

យឹម ៖ នារីកងចល័ត ។

វណ្ណៈ ៖ កងចល័តនៅណាដែរមីង? នៅស្រុក...

យឹម ៖ កងចល័តនៅ នៅភូមិហ្នឹង ។

វណ្ណៈ ៖ ភូមិអីគេ?

យឹម ៖ នៅភូមិ មុនដំបូងគេរើសនៅតាមភូមិចឹង កាលគេអត់ទាន់យកទៅណា នៅភូមិត្រពាំងរន្ធហ្នឹង ។

វណ្ណៈ ៖ ភូមិត្រពាំងរន្ធ ។

យឹម ៖ នៅបានយូរ បានប្រហែល៣ឆ្នាំ ។

វណ្ណៈ ៖ ត្រពាំងរន្ធហើយ មីងចេញពីកងចល័ត អីពេលធ្វើកងចល័តហើយ ប្រហែលជាពេលណាបានគេហៅមីងទៅធ្វើពេទ្យហ្នឹង? ធ្វើកងចល័តបានយូរទេ?

យឹម ៖ ចេញពីកងចល័តហើយទៅធ្វើពេទ្យហ្នង ធ្វើពេទ្យហ្នឹងបានប្រហែលជា៥ ៤ឆ្នាំទេ ។

វណ្ណៈ ៖ ហ៎ បានយូរម៉េស អាពតបើអាពតតែ៣ឆ្នាំហ្នឹង?

យឹម ៖ អូ! អាពត៣ឆ្នាំហី? អូចឹង មើល៎ចុះមកចឹងនៅធ្វើកងចល័តប្រហែលជា១ឆ្នាំ បានឡើងទៅទៀត ដល់នេះ ។

វណ្ណៈ ៖ អូចឹង ប្រហែលជា៧៦មីងធ្វើពេទ្យហើយ?

អ្នកចូលរួមៈ ធ្វើដែរ ប្រហែល២ឆ្នាំ ។

យឹម ៖ ហ្នឹងហើយ ប្រហែលប៉ុណ្ណឹង ។

វណ្ណៈ ៖ ចឹងឆ្នាំ១៩៧៦ ធ្វើពេទ្យ ទៅធ្វើពេទ្យហ្នឹងគេមករើសតាមកង ឬក៏ម៉េច?

យឹម ៖ គេរើស គេជ្រើសៗ ។

វណ្ណៈ ៖ ពីណាមករើស?

យឹម ៖ ទេក្រុមគេ មិនមែនអ្នកធំមករើសទេ ក្រុមគេទេភ្លេចមិនដឹងឈ្មោះអីៗទេ មេក្រុមគេដើររើស ជ្រើសៗពីកងចល័តទៅចឹងទៅ ។

វណ្ណៈ ៖ ហើយយកទៅធ្វើពេទ្យចឹងហ្នង គេប្រាប់?

យឹម ៖ គេហៅ ហ្នឹងហើយគេហៅថាទៅធ្វើពេទ្យធ្វើអី ប៉ុនមិនបានទៅរៀនទៅអីផងហ្នឹង ។

វណ្ណៈ ៖ បាទ! ចុះពេលកំពុងតែធ្វើនៅកងចល័តចឹង ស្រាប់តែគេប្រាប់ថាហ៎ឈ្មោះនេះមួយ...

យឹម ៖ ហ្នឹងហើយ ហៅ ។

វណ្ណៈ ៖ ទៅធ្វើពេទ្យ មីងសប្បាយចិត្តអត់កាលហ្នឹង?

យឹម ៖ សប្បាយចិត្ត បើថាខ្លួនមិនសូវចេះ មានសប្បាយចិត្តអី មិនដឹងទៅព្យាបាលគេរបៀបម៉េចផងហ្នឹង ប៉ុនដល់គេហៅម៉េចហ៊ានប្រកែក អូនឯងម៉េចហ៊ានប្រកែកថាយើងមិនទៅ ។

វណ្ណៈ ៖ បាទ!

យឹម ៖ មិនបានទៅរៀនថាឲ្យដឹងថាយ៉ាងម៉េចៗ ជម្ងឺអីចាក់អី ចេះតែទៅៗទៅណា គេហៅយើងអត់ហ៊ានប្រកែកទេ ។

វណ្ណៈ ៖ អញ្ចឹង?

យឹម ៖ ចា៎!

វណ្ណៈ ៖ ហើយយើងចេះតែទៅៗ ភ័យផង ។

យឹម ៖ ចា៎!

វណ្ណៈ ៖ មិនមែនអរទេ?

យឹម ៖ ភ័យតើ ព្រោះខ្លួនមិនចេះ ថីមិនភ័យ...

វណ្ណៈ ៖ មិនអរ?

យឹម ៖ មិនអរទេ នឹកឃើញថាមិនដឹងទៅមើលអ្នកជម្ងឺយ៉ាងម៉េច បើខ្លួនអត់ចេះផង មិនទាន់ដឹងមិនដែលទៅរៀនទៅអីផង ហើយយកទៅ ។

វណ្ណៈ ៖ បាទ! ចឹងដល់ពេលទៅដល់ដំបូងហ្នឹង អត់ទៅធ្វើពេទ្យឃុំពេទ្យអីសិនទេ? ទៅដល់ពេទ្យស្រុកហ្មង?

យឹម ៖ អត់ទេ គេហៅទៅកន្លែងស្រុកហ្នឹងហ្មង ។

វណ្ណៈ ៖ ទៅពេទ្យស្រុកហ្នឹង...

យឹម ៖ ចា៎ពេទ្យស្រុកនៅ គិរីវង្ស ។

វណ្ណៈ ៖ មីងមានឃើញមនុស្ស បុគ្គលិកពេទ្យហ្នឹងច្រើនគ្នាទេ?

យឹម ៖ បុគ្គលិកពេទ្យហ្នឹង ថាទាំងអ្នកដាំបាយទាំងអីហ្នឹងវាម្ភៃជាង ព្រោះម៉ានបន្ទប់ដែរហ្នឹងណាអ្នកជម្ងឺណាអូន ។

វណ្ណៈ ៈ បាទ! ចឹងបើតាមរបស់មីង ស្តាប់ទៅខ្ញុំជួបជាមួយពេទ្យឃុំ ពេទ្យឃុំប្រហែលជាច្រើនដាងចឹង?

យឹម ៈ ពេទ្យឃុំច្រើន ហើយដល់ពេលជ្រើសហ្នឹងគេជ្រើសពីខ្ញុំទៅចឹងអត់មានចូលឃុំទេខ្ញុំ នៅកន្លែងស្រុកហ្នឹងហ្នង ។

វណ្ណៈ ៈ បាទ! ដាងម្តៃវណ្ណៈហ្នឹង មានប្រុសប្រហែលប៉ុន្មានដែរ?

យឹម ៈ ប្រុស៥-៦នាក់ទេ ប្រុសតិចដាងស្រី ។

វណ្ណៈ ៈ ដំបូងណា យើងចូលទៅដំបូងហ្នឹងគេមានហៅមីងទៅបង្រៀនសិន ឬក៏គេហៅទៅចាក់ថ្នាំផ្ទាល់ហ្នង?

យឹម ៈ អត់ទៅបង្រៀនទៅអីទេ គ្រាន់ថាដូចថាដើរតាមគេ គេប្រធានគេអីគេចេះចឹង យើងមើលគេ ។

វណ្ណៈ ៈ ដំបូងដើរតាមគេសិន?

យឹម ៈ ចា៎! ដើរតាមគេសិនបានគេប្រាប់ថាចាក់អញ្ចេះៗដែរហ្នឹងណា ។

វណ្ណៈ ៈ ដំបូង ។

យឹម ៈ ដើរតាមគេហ្នឹង អត់មាន ។

វណ្ណៈ ៈ ដើរតាមមើលគេសិន?

យឹម ៈ ចា!

វណ្ណៈ ៈ ដើរតាមមើលហ្នឹងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

យឹម ៈ លឿនទេ ប្រហែលជាមិនដល់ដប់ថ្ងៃទេ គេឲ្យយើងចាប់ផ្តើមធ្វើនេះហើយ ចែកថ្នាំគ្រាប់ថ្នាំអីហើយ ។

វណ្ណៈ ៈ ផ្តាំឲ្យយើងធ្វើហ្នឹងយកថ្នាំគ្រាប់ឲ្យអ្នកជម្ងឺអ៎?

យឹម ៈ ចា៎! ដើរតាមព្យាបាលអ្នកជម្ងឺ ។

វណ្ណៈ ៈ នៅក្នុងពេលមីងទៅហ្នឹង ពេលដែលអីទៅដល់ហ្នឹងដូចថាមានពេទ្យយកថ្នាំឲ្យអ្នកជម្ងឺហ្នឹង តើមីងសង្កេតឃើញថាអ្នកជម្ងឺប្រភេទណាច្រើនជាង?

យឹម ៈ ទេជំនាន់ហ្នឹងដូចថា អ្នកជម្ងឺវាច្រើនតែអត់ឃ្លាន ខ្វះជីវជាតិស្គមៗអីហ្នឹង ហើមៗ ច្រើនហើមអួន ។

វណ្ណៈ ៈ ចឹងភាគច្រើនហើម?

យឹម ៈ វាអត់មានជាតិវីតាមីននោះ ។ ព្យាបាលហ្នឹង ជម្ងឺហើមច្រើនហើម ហើមពោះហើមអី ។

វណ្ណៈ : ចឹងអាជម្ងឺបែបហ្នឹងពិបាកព្យាបាលទេ?

យឹម : មិនសូវជាដែរអូន ជម្ងឺហ្នឹង ។

វណ្ណៈ : មិនសូវមានជាទេ?

យឹម : មិនសូវមានជាទេ ភាគច្រើនស្លាប់ ព្រោះអត់ជាតិវីតាមីនហ្នឹង ដល់នេះពោះសុទ្ធតែទឹក សុទ្ធតែអី ហើមជ្រាចៗនេះអត់សូវជាដែរ ។

វណ្ណៈ : បាទ! ចឹងឧបមាថា នៅមន្ទីរពេទ្យហ្នឹង មានដូចថាពេទ្យស្រុកគ្មានលទ្ធភាពព្យាបាល មានបញ្ជូនទៅ ឬក៏អត់បញ្ជូនទេ បញ្ជូនទៅលើទៀត ?

យឹម : មិនសូវបញ្ជូនទៅតាកែវទេ ច្រើនតែស្លាប់នៅផ្សារគិរី គេធ្វើ ។

វណ្ណៈ : មិនសូវបញ្ជូនទេ?

យឹម : ចា៎! ដល់ស្លាប់ទៅ គេធ្វើកន្ទែលដុតនៅពីខាងត្បូងផ្សារហ្នឹង ចេះតែយកទៅដុតទៅអីមិនសូវបញ្ជូនទេ ព្រោះមិនសូវមានឡានមានអីណាបញ្ជូនផង ។

វណ្ណៈ : ចឹងច្រើនតែស្លាប់នៅៗស្រុក?

យឹម : នៅផ្សារហ្នឹង ពេទ្យគិរី ពេទ្យស្រុកហ្នឹង ។

វណ្ណៈ : ចឹងមីងដូចថា កាលហ្នឹងថ្នាំភាគច្រើនថ្នាំអីដែរ?

យឹម : ថ្នាំដូចគេថា ។

វណ្ណៈ : ថ្នាំអាចម៍ទន្សាយ ។

យឹម : អាជបហ្នឹងគេដាក់កងហូ ដាក់អីចឹងទៅ ដាក់វីតាមីនសេ ។

វណ្ណៈ : ចុះមានថ្នាំអាចម៍ទន្សាយទេ?

យឹម : ចា៎? អាចម៍ទន្សាយហ្នឹងថ្នាំគ្រាប់អូន ថ្នាំគ្រាប់លេបហ្នឹងដូចថា លេបទៅ ឈឺក្បាលអីចឹងចែកជាថ្នាំគ្រាប់អត់មានថ្នាំបរទេសទេ ថ្នាំស្លជាគ្រាប់ហ្នឹងណា ។

វណ្ណៈ : ថ្នាំខ្លួនឯងហ្នឹង?

យឹម : របៀបថ្នាំស្ល ឬសឈើហ្នឹងណា ប៉ុនមិនដឹងថាលេបទៅជាឬមិនជាទេ អ្នកជម្ងឺវាច្រើនដាក់ក្រោមកន្ទេលមិនសូវលេបផងហ្នឹង វាដូចពិបាក ។

វណ្ណៈ : ម៉េចចឹងណ៎?

យឹម : វាមិនសូវលេបណា បានវាមិនសូវជាដែរ ហើយថ្នាំក៏គ្មានប្រសិទ្ធិភាពអីដែរ ចេះតែស្លចាក់ជាគ្រាប់ ដូចគ្រាប់យើងចឹង ប៉ុនថ្នាំឬសឈើហ្នឹងណា មានមត់ណាត្រើមៗដែរហ្នឹងគេលុញ គេកិនជាម្សៅ ហើយបានគេបោះជាគ្រាប់ ។

វណ្ណៈ : បើតាមមីងដឹង ពីរបៀបធ្វើមីងមានដឹងខ្លះទេ គេយកស្អីធ្វើខ្លះ?

យឹម : អត់ដឹងទេអូន ព្រោះកន្លែងខុសគ្នាយើងមិនអាចដឹងទេណា យើងគ្រាន់តែគេយកមកឲ្យចឹង គេប្រាប់ថាជម្ងឺនេះត្រូវឲ្យលេបថ្នាំនេះទៅ ថ្នាំចាក់អីបិទផ្សាកនៅនឹងដបទឹកក្រូចចឹងទៅ ។

វណ្ណៈ : ចុះប្រធានពេទ្យ ពីណាគេ?

យឹម : ប្រធានធំនោះគេនៅ នៅឆ្ងាយហ្នឹងដូចខ្ញុំប្រាប់នោះ ។

វណ្ណៈ : ឈ្មោះអីគេ?

យឹម : ឈ្មោះ កេន ប្រពន្ធតាទិតនោះ នៅតើ ។

វណ្ណៈ : ឈ្មោះ កេន ។

យឹម : ចា៎! យាយកេនហ្នឹងប្រធានខ្ញុំ ប្រធានពេទ្យនោះ ។

វណ្ណៈ : គាត់ត្រូវជាមួយម៉េច តាម៉ុក?

យឹម : ពោះមួយជាមួយតាម៉ុក ។

វណ្ណៈ : ហ្អាក៎! ប្អូនតាម៉ុកចឹង?

យឹម : ប្អូនតាម៉ុក ។

វណ្ណៈ : ឈ្មោះអី?

យឹម : ឈ្មោះយាយកេន ។

វណ្ណៈ : កេនហ្នឹងប្អូន តាម៉ុក?

យឹម : ចា៎! ហើយប្តីគាត់ហ្នឹងឈ្មោះ តាទិត ។

វណ្ណៈ : តាទិត ហ្នឹងប្តី?

យឹម : តាទិតហ្នឹងប្តី យើងយាយកេនហ្នឹងប្អូនថ្លៃ តាម៉ុក ។

វណ្ណៈ : អូ! ចឹងឈ្មោះកេន ។

យឹម : ឈ្មោះកេន ហ្នឹងហើយ កេនហ្នឹង ។

វណ្ណៈ : ប្អូនតាម៉ុកបង្កើត?

យឹម : ចា៎! ថាពោះមួយបង្កើត បង្កើតហ្នឹងតែឥលូវមិនដែលជួបគ្នាទេ តែគេថាយាយកេនហ្នឹងពោះមួយតាម៉ុកចឹង ។

វណ្ណៈ : ចុះអ៊ី យាយកេន តាទិតហ្នឹងសព្វថ្ងៃនៅរស់ដែរតើអី?

យឹម : កាលនេះគាត់នៅរស់ បងប្អូនដុះនេះ ឥលូវមិនដឹងម៉េចទេ យូរឆ្នាំហើយ ។

វណ្ណៈ : នៅរស់តែមិនដឹងនៅណា?

យឹម ៖ ចា៎! នៅរស់ តែមិនដឹងនៅណា ។

វណ្ណៈ ៖ ចុះបន្ទាប់ពីយាយកេនហ្នឹង?

យឹម ៖ បន្ទាប់ពីយាយកេនហ្នឹង ប្រុសឈ្មោះភ៉ាន់ នៅភូមិត្រយឹង ។

វណ្ណៈ ៖ អនុប្រធានហ៎?

យឹម ៖ ចា៎! ចុះមក ។

វណ្ណៈ ៖ ឈ្មោះយាយភ៉ាន់ហ៎?

យឹម ៖ ពូ!

វណ្ណៈ ៖ ពូភ៉ាន់!

យឹម ៖ ពូភ៉ាន់ នៅឯភូមិត្រយឹង នៅរាមអណ្ដើកដែរ ។

វណ្ណៈ ៖ ពូភ៉ាន់ហ្នឹងអី! យាយកេន ពូភ៉ាន់ហ្នឹងគាត់កាន់ពេទ្យរហូត ដល់៧៩?

យឹម ៖ កាន់ៗ រហូតដល់បែកហ្វូង ។ យាយកេនហ្នឹងគាត់ចេញយូរហើយ យាយកេនហ្នឹងចេញពីហ្នឹងយូរហើយតែនៅតាភ៉ាន់ ពូភ៉ាន់ ហ្នឹងនៅព្យាបាលដល់ពេលបែកហ្វូង ។ ហ្នឹងហើយភ៉ាន់ហ្នឹងបាននៅជាប់ នៅផ្សារគីរី ។

វណ្ណៈ ៖ យាយកេនបានផ្លាស់ប្ដូរហ៎?

យឹម ៖ ហ្នឹងហើយ!

វណ្ណៈ ៖ គាត់ចេញឆ្នាំណា?

យឹម ៖ ភាអត់ដឹងឆ្នាំទៀត គាត់ដូរចេញពីពួកខ្ញុំហ្នឹងយូរឆ្នាំដែរណា យូរដែរបានបាត់អាយ៉ូយ៉ាហ្នឹង (រញ៉េរញ៉ៃ) គាត់ទៅពីតូច ។

វណ្ណៈ ៖ ដូរចេញទៅប្រហែលជាឆ្នាំ ។

យឹម ៖ ដាក់ស្មានៗអូន គ្មានដឹងទេ ។

វណ្ណៈ ៖ កាលហ្នឹងៗ យាយកេនហ្នឹង មីងជួបប្រហែលប៉ុន្មានឆ្នាំ?

យឹម ៖ ខ្ញុំនៅជាមួយគាត់តែ១ឆ្នាំជាងទេ ។

វណ្ណៈ ៖ ឆ្នាំប្រហែលជាឆ្នាំ៧៧ យាយកេនចេញ?

យឹម ៖ ចា៎!

វណ្ណៈ ៖ មានដឹងគាត់ចេញទៅណាទេ?

យឹម ៖ ចេញទៅគាត់ គ្រួសារគាត់ដកទៅគាត់ចេញ មិនដឹងចេញទៅណាដែរណា គ្រួសារគាត់ធ្វើការដែរគាត់ទៅ ។

វណ្ណៈ ៖ ចេញទៅជាមួយប្ដីគាត់?

យឹម ៖ ចាំ!

វណ្ណៈ ៖ ចឹងអត់ដឹងថាគាត់ទៅកាន់នៅណា ណាអី?

យឹម ៖ គាត់ឈប់ធ្វើពេទ្យហើយ គាត់ទៅតាមប្ដីគាត់ហើយ កាលនៅជាមួយគ្នាគាត់គ្រាន់តែកាន់ដូចថាប្រធានពេទ្យចឹងណាអូន ដល់គាត់ទៅដូចថាមិនដឹងឆ្នាំណា ហើយមិនដឹងថាគាត់ទៅហ្នឹងធ្វើអីក៏មិនដឹងដែរ ។

វណ្ណៈ ៖ បាទ! ចឹងមានតែរ៉ាន់ យាយកេនទេដែលធំជាងគេនៅពេទ្យហ្នឹង?

យឹម ៖ ចាំ! នៅពេទ្យហ្នឹង ។

វណ្ណៈ ៖ ចឹងគាត់ដែលហៅ ដូចថាបុគ្គលិកពេទ្យប្រជុំរបៀបម៉េច?

យឹម ៖ ប្រជុំដូចថា ប្រជុំអាណាខុស អាណាអីហ្នឹងណា តែប្រជុំនៅក្រុម នៅក្នុង ។

វណ្ណៈ ៖ ប្រជុំរាល់ថ្ងៃ ឬក៏ម៉ោអាទិត្យប្រជុំម្ដង?

យឹម ៖ មិនទេ យូរៗបានប្រជុំ ដូចថាប្រជុំជីវភាពគេ ។

វណ្ណៈ ៖ ប្រហែលប៉ុន្មានថ្ងៃ ៧ថ្ងៃ?

យឹម ៖ ៧ថ្ងៃអីចឹងហៅប្រជុំម្ដង ចឹងនៅក្រុមនៅផ្សារគិរីហ្នឹង ។

វណ្ណៈ ៖ រយៈពេល៧ថ្ងៃប្រជុំម្ដង ។ ចឹងបុគ្គលិកពេទ្យធម្មតា ដូចមីងដូចអីចឹងដូចថាមានការផ្លាស់ប្ដូរ ឬក៏នៅហ្នឹងរហូតដល់៧៩ដែរ?

យឹម ៖ ខ្ញុំពីមុនដំបូង គេរើសទៅដល់នៅពោធិអុងហ្នឹង ហើយបានមកនៅគិរីបាននៅជាប់រហូតអត់មានផ្លាស់ទៅណាទៀតផង ។

វណ្ណៈ ៖ ចុះក្រៅពីមីង មានបុគ្គលិក?

យឹម ៖ មានផ្លាស់ប្ដូរដែរហ្នឹង ដូចថានៅជាមួយគ្នាហ្នឹង គេត្រូវដកទៅនេះទៅនោះអីដកចឹងទៅ ហើយបើខ្ញុំវិញនៅគិរីហ្នឹង ។

វណ្ណៈ ៖ ចុះបើដកទៅហ្នឹង មានបុគ្គលិកបន្ថែមទៀតទេ?

យឹម ៖ បន្ថែមតើ ដូចដូរគ្នាចឹងណា ។

វណ្ណៈ ៖ ចូលបុគ្គលិកថ្មីវិញ?

យឹម ៖ ចាំ! គេប្ដូរគ្នាវិញ ។

វណ្ណៈ ៖ ចុះមីងកាលជំនាន់ហ្នឹង មីងមានដែលឃើញតាម៉ុក ឬក៏ពីណាអីមក?

យឹម ៖ អត់ស្គាល់ទេ តាម៉ុកហ្នឹង ។

វណ្ណៈ : អត់ស្គាល់ទេ?

យឹម : ចា៎! អត់ដែលឃើញផង ។

វណ្ណៈ : អត់ស្គាល់ទេហ៎?

យឹម : អត់ដែលឃើញសោះ គ្រាន់តែឮឈ្មោះហ្នឹង មិនដែលឃើញទេ គេមកនៅចិនគេម៉េចមក មក ស្រុកចិន មកចិនគេមិនសូវហ៊ានមកដែរណា ។

វណ្ណៈ : បាទ!

យឹម : អត់ដែលឃើញទេ ឮតែឈ្មោះ ។

វណ្ណៈ : អត់ទេ កាលជំនាន់ប៉ុលពតហ្នឹង?

យឹម : ហ្នឹងហើយ ជំនាន់ប៉ុលពត ហ្នឹងអត់ដែរឲ្យឃើញ ឲ្យជួប ។

វណ្ណៈ : អត់ចុះ?

យឹម : ហ្នឹងហើយអត់ដែលចុះជួបទេ ។

វណ្ណៈ : ចុះមានដែលឃើញគណៈប្រតិភូប្លែកៗចុះមកមើលតាមមន្ទីរ?

យឹម : មានតែត្រឹមនេះស្រុកហ្នឹង បើថាធំៗយើងមិនជួបទេ យើងទៅកន្ត្រឹកកន្ត្រៃចិន ម៉េចគេ ម៉េចមកជួប ។

វណ្ណៈ : ចុះឧបមាថាថ្នាក់ស្រុកអី ត្រឹមគាទិតអីហ្នឹងគាត់មកនិយាយជាមួយពេទ្យថា ឲ្យយើង ព្យាបាលមនុស្សយ៉ាងម៉េច របៀបម៉េចអីគាត់មានដាក់បញ្ហាទេ?

យឹម : គាត់អត់បញ្ហាទេគាត់គ្រាន់តែប្រាប់ឲ្យក្រុមហ្នឹងប្រជុំ មើលអ្នកជម្ងឺមើលអីចឹង ធម្មតាចឹង ទៅត្រឹមស្រុក បើថាអ្នកធំក្រៅពីហ្នឹងមិនដែលជួបផង ។

វណ្ណៈ : ចឹងយើងមានដែលមានប្រធានពេទ្យនៅកន្លែងមីង ប្រធានពេទ្យតូចតាចទៀតបន្ទាប់ពី?

យឹម : ទាល់ប្រធានក្រុមអីចឹងទៅ ។

វណ្ណៈ : ប្រធានក្រុមណា មានដែលលើកសំណើទៅថាអញ្ចេះ ថាឥលូវប្រជាជនមកច្រើនហើយ គ្នាខ្វះថ្នាំ ខ្វះអីមានដែលលើកសំណើទៅឲ្យស្រុកដឹងទេ?

យឹម : យើងតែអស់ថ្នាំ អស់អីហ្នឹងយើងប្រាប់គេចឹងដែរ ។

វណ្ណៈ : ប្រាប់ទៅគេយកចិត្តទុកដាក់ ឬក៏យ៉ាងម៉េច?

យឹម : ហ្នឹងហើយ គេដល់ថាអ្នកជម្ងឺច្រើនចឹងអត់ថ្នាំអត់អី យើងប្រាប់ទៅគេផ្ញើរមកឲ្យចឹង គ្រាន់ ថាចាក់ត្រូវមិនត្រូវ យើងអត់ដឹងដែរណា ថ្នាំបានមកប្រើចឹងដែរណា៎ ។

វណ្ណៈ ៖ ចុះឧបមាថាអ្នកជម្ងឺភាគច្រើនឈឺហើយមិនសូវបានរស់ត្រឡប់ទៅវិញទេ ហើយយើងរាយការណ៍ទៅចឹង តើអង្គការយកចិត្តទុកដាក់ថែមទៀតទេ?

យឹម ៖ អង្គការវាគ្មាននេះទេ គ្រាន់ប្រាប់ថានៅមើល ។

វណ្ណៈ ៖ បើស្លាប់ក៏ស្លាប់ទៅ?

ហឹម ៖ នៅនឹងនៅហ្នឹងហើយ ស្លាប់អីណាមានម៉ែឪ នៅជិតកូនចៅអឹមកយកទៅ បើអត់មកយកដុតចោលអីទៅ ។

វណ្ណៈ ៖ ចឹងពេលស្លាប់អត់មានជូនដំណឹងអីទេ?

យឹម ៖ អត់ជូនដំណឹង គ្មានដឹងជូនដំណឹងអីទេ ស្លាប់ៗទៅមិនដឹងកូនចៅនៅណាផង ។

វណ្ណៈ ៖ ចឹងកប់ចោលហ្នឹង?

យឹម ៖ បើអ្នកនៅជិត ដូចថានៅជិតពេទ្យអីដឹងដំណឹងកូនចៅទៅមើល បានយកមកផ្ទះកប់ទៅ បើនៅឆ្ងាយអត់មានកប់ផង ដាក់ដុត ដុតឡគេចូលទៅ ដាក់ក្នុងឡ ។

វណ្ណៈ ៖ ចឹងប្រជាជនហ្នឹង មើលទាំងកម្មាភិបាល មើលទាំងប្រជាជនយើងធម្មតា ។

យឹម ៖ មើលតែប្រជាជន ។

វណ្ណៈ ៖ ចុះក្នុងពេទ្យៗ ការហូបចុកក្នុងពេទ្យ?

យឹម ៖ ការហូបចុកក្នុងពេទ្យ អ្នកជម្ងឺហូបបបរ ហូបអី បើជម្ងឺធ្ងន់ហូបបបរអ្នកនេះ សម្លត្រកួនសម្លអីចឹងទៅ បាយ បបរគ្រាន់ថាបបរវាគោក ។

វណ្ណៈ ៖ ចុះបុគ្គលិកពេទ្យយើងហូបអីដែរ?

យឹម ៖ បុគ្គលិកពេទ្យហូបដូចគ្នា មិនហូបខុសគ្នាទេ គ្រាន់ថាបាយបបររៀងរឹងតិច សម្លត្រកួនសម្លព្រលិតហូបដូចតែគ្នា ។

វណ្ណៈ ៖ ដូចអ្នកជម្ងឺដែរចឹង?

យឹម ៖ ចា៎! ហូបដូចគ្នា ។

វណ្ណៈ ៖ ចុះមីងគិតថាមីងបុគ្គលិកពេទ្យធម្មតាហូបអញ្ចឹង អ្នកជម្ងឺហូបចឹង ចុះមីងជឿថាអ្នកដែលប្រធានពេទ្យ ឬក៏គណៈស្រុក ឬក៏គណៈដូចយាយកេន យាយអីហ្នឹងមកហូបបាយហូបបបរអី ជាមួយយើងដែរ ឬក៏អាចបាយសុទ្ធ បាយអី បើតាមមីងគិតណា?

យឹម ៖ គិតថាគេមិនហូបដូចយើងទេ គេអ្នកនេះគេម៉េចហូបដូចយើង គេហូប គេមិនដែលហូបជាមួយយើងផង គេហូបៗឆ្ងាញ់ជាងយើងហើយទោះមានមាន់មានអី គេកាប់ហូបតែគេ

ទៅ អ្នកបុគ្គលិកនៅនេះ ហូបធម្មតាជាមួយអ្នកជម្ងឺចឹងទៅ មិនដែលបានហូបឆ្ងាញ់លើស អ្នកជម្ងឺផង ។

វណ្ណៈ : ចឹងអត់មានហូបចុកដូចគ្នាទេ ចឹងមែន? ចុះខ្មែរក្រហមថា ។

យឹម : ប្រហែលដោយកន្លែងទេអូន ។

វណ្ណៈ : យើងបង្កើតសង្គមមួយឲ្យមាន ឲ្យការហូបចុកដូចគ្នា តើមីងគិតថានៅក្នុងរបបហ្នឹងដែលខ្មែរ ក្រហមនិយាយចឹង មីងគិតថា អាចហូបដូចគ្នា ឬក៏មានឋានៈខុសគ្នា?

យឹម : ឋានៈគ្រាន់អ្នកធំ បើត្រឹមខ្ញុំអីហ្នឹងជាមួយអ្នកជម្ងឺ ដូចគ្នា ។

វណ្ណៈ : ចឹងនៅតែអត់ស្មើគ្នាដដែល?

យឹម : អត់ស្មើគ្នាទេ គេអ្នកធំគេម៉េចហូបដូចយើង គេធ្វើហូបមិនធ្វើដោយផ្សេងទៀត យើង ពេទ្យតូចតាចចឹងហូបតែជាមួយអ្នកជម្ងឺហ្នឹង បាយតែបបរគោកៗហ្នឹង ។

វណ្ណៈ : ចុះដូចនៅក្នុងសម័យហ្នឹងដែរណា តើមីងព្យាបាលដែលឃើញជួបបងប្អូនខ្លួនឯងអីទេ?

យឹម : មានជួបនៅស្រុក នៅភូមិអីចឹងដែរ

វណ្ណៈ : ជួបឯណា?

យឹម : ប៉ុនដល់ជួបហ្នឹងគេមានឲ្យយើងជិតដាល ថាថៃមាន ស្អីអោយៗដែរ ដូចថាខ្ញុំមានពូខ្ញុំឈឺ ចឹងអី យើងធ្វើមិនសូវដឹងដែរណា គានេះហ្នឹងគេថា យើងមើលបងប្អូនយើង ។

វណ្ណៈ : ចឹងមីងដូចថាអ្នកជម្ងឺកាលហ្នឹង ដូចថាភាគច្រើនឈឺហើមទេ ចុះជម្ងឺផ្សេងៗទៀតមិនសូវ ទេ?

យឹម : ខ្ញុំអត់ព្យាបាលជម្ងឺផ្សេង ដូចថាអ្នកពោះពោះអីអត់មាននៅជាមួយខ្ញុំទេ យាយមួយនៅ ផ្ទះត្បូងនោះគាត់អ្នកទទួល ខ្ញុំព្យាបាលអ្នកជម្ងឺទូទៅ ឈឺហើមៗទូទៅហ្នឹងណា គាត់ខាងឆ្មប ចាងឆ្មបចឹងទៅ ។

វណ្ណៈ : បាទ! ចុះដូចអ្នកជម្ងឺយកទៅដល់មន្ទីរពេទ្យស្រុកហើយណា តើដូចថាកន្លែងពេទ្យហ្នឹង មាន ដូចថាគ្រែធម្មតា មានអនាម័យមានអីដែរ ឬក៏អត់មិនសូវទេ?

យឹម : មាន! គេមានគ្រែឲ្យដេកតាមត្រឹមត្រូវដែរណា ។

វណ្ណៈ : ត្រឹមត្រូវដែរ?

យឹម : ចាំ! មានក្រាលកន្ទេលក្រាលអី ដេកត្រឹមត្រូវដែរអ្នកជម្ងឺ ។

វណ្ណៈ : អត់មានគ្រែមានអី?

យឹម : មាន! មានគ្រែដូចពេទ្យយើងឥលូវ ប៉ុន្តែគ្រែចាស់ៗហ្នឹងណា គ្រែតូចៗដេកមិនមែនដូចពេទ្យយើងឥលូវ មែនគ្រែដែកល្អអី មានគ្រែដេកម្នាក់ ២នាក់គេថែអីចឹង ប៉ុនមិនសូវឲ្យគេថែទេ ដល់ជម្ងឺធ្ងន់បងប្អូនគេនៅជិតអី បានហៅសុំគេឲ្យបងប្អូននៅថែ បើចឹងកូនត្រូវធ្វើការនៅកងចល័តអី ធ្វើការមានផ្នែកៗអី គេអត់ឲ្យទេ ទាល់ថាជិតទៅអីកូនហ្នឹងសុំគេទៅគ្រាន់ថាគេចិត្តល្អ គេឲ្យមកថែទៅ មិនឲ្យមកថែបើគាត់ជិតដាច់ខ្យល់អីចឹង មិនដឹងដែរហ្នឹងណា ប៉ុន្តែអ្នកជិតៗដឹង ប៉ុនមនុស្សមកពីឆ្ងាយអីអត់ដឹងទេ យកទៅកប់អីហ្នឹង ដឹងដោយសារអ្នកឆ្ងាយ អ្នកជិតអត់ឲ្យដឹងទេ ដឹងកូនចៅគេមកសុំយកទៅកប់ទៅអីតាមផ្ទះហ្នឹងបានអត់មានធ្វើបុណ្យធ្វើអីទេកាលហ្នឹង ។

វណ្ណៈ : កាលហ្នឹងអត់ទេ?

យឹម : អត់ទេអូន ។

វណ្ណៈ : អោយតែបានកប់ បានដឹងហ្នឹងគ្រាន់បើហើយ ។

យឹម : អោយតែបានសព ដូចថាសពម្ដាយអីហ្នឹង ឲ្យតែសុំគេសែងតាមអង្រឹងតាមអី យកមកទុកនៅផ្ទះមក ។

វណ្ណៈ : បាទ! ចុះមីងនៅធ្វើពេទ្យហ្នឹង តើមីងមានដឹងថាខាងក្រៅមានការអត់ឃ្លានសម្លាប់មនុស្សអីមីងមានដឹងទេ កាលហ្នឹងនៅពេទ្យ?

យឹម : វាខុសផ្នែកគ្នា គ្រាន់ពុថាវាមិនដែលជួបប្រទះឃើញផ្ទាល់ភ្នែកទេអូន គ្រាន់ថាយើងផ្នែកពេទ្យៗទៅ អ្នកកន្លែងគេសម្លាប់គេអីហ្នឹងដោយខ្លួន ប៉ុនយើងអាចដឹងដូចគ្នាហ្នឹង ថាពួកវាអត់បាយខ្លះស្លាប់ ខ្លះវាសម្លាប់តាមអញ្ចេះអញ្ចុះអីហ្នឹង វាដឹងដូចគ្នាគ្រាន់តែយើងមិនដែលឃើញផ្ទាល់ណាអូន ។

វណ្ណៈ : បាទពុ កាលក្នុងសម័យហ្នឹងណាពុ ។

យឹម : ហ្នឹងហើយពុ សម័យហ្នឹងពុគេ ។

វណ្ណៈ : ពុសម័យហ្នឹងប៉ុន្តែ គ្រាន់ៗតែដឹងតាមគ្នាតិចតួច តែអត់ហ៊ាននិយាយអីទេ ។

យឹម : ដឹងៗ តែអត់ហ៊ាននិយាយអីទេ ព្រោះទោះសម្លាប់បងប្អូន បងប្អូនទៅដេកពេទ្យអីចឹង អត់ប្រាប់គេថាបងប្អូនដងតែគេដឹងថាបងប្អូន គេមិនទុកចិត្តទៀតខ្លាចយើងឲ្យថ្នាំអីល្អៗអីចឹងមិនសូវហ៊ានឲ្យដឹងដែរហ្នឹងណា បើថាបងប្អូននៅស្រុកភូមិអីទៅដេកហ្នឹង អត់ឲ្យដឹងទេ គេប្រធានអី យើងមិនសូវឲ្យដឹងដែរហ្នឹងណា ។

វណ្ណៈ : ចុះក្នុង១ថ្ងៃ អាហារអ្នកជម្ងឺប៉ុន្មានដងដែរ?

យឹម ៖ ពេលព្រឹកចឹងដូចថា អ្នកឈឺអីចែក១វែកៗឲ្យហូបចឹងទៅ ថ្ងៃត្រង់អីចឹង ហូប៣ដងដែរ ហ្នឹងណាអ្នកឈឺ ។

វណ្ណៈ ៖ ចុះបើសិនជាពេទ្យ?

យឹម ៖ ពេទ្យវាដូចថាមិនសូវនេះទេ ។

វណ្ណៈ ៖ ៣ពេលដូចគ្នាណា?

យឹម ៖ ហូបធម្មតាចឹងទៅ ប៉ុនវាគ្មានម្ហូបឆ្ងាញ់ទេ ដូចថាបបចឹង ស្ងចឹងចេះតែហូបនឹងគេ តែហេវ ហូបនឹងគេហើយ វាអត់មានកំណត់ទេហ្នឹង ចេះហូបវាមិនអត់ឃ្លានតាម វាគ្រាន់តែថាហូប ម៉ាចម្ទេសអី វាគ្មានជាតិអីទេ សម្លព្រលិត សម្លត្រកួនដឹងហើយជនាន់ហ្នឹង មិនមែនដូច សាច់ជ្រូកសាច់គោឯណា ។

វណ្ណៈ ៖ បើតាមមីងសង្កេតឃើញ ធ្លាប់នៅពេទ្យហ្នឹងរហូតមកហ្នឹង តើមីងធ្លាប់ឃើញដូចថាអ្នកជម្ងឺ ណាមួយ ដូចថាសុំឲ្យពេទ្យជួយជង ឬមួយធ្វើយ៉ាងម៉េច សំណូមពរអីដល់ពេទ្យអីមានទេ?

យឹម ៖ មានដែរ! មានដូចថាគាត់ចេះតែសួរ សុំចឹងទៅ បើពេទ្យណាវាចិត្តល្អ វាយកបាយទឹកអី យកចេញមកក្រៅឲ្យចឹងក៏មានដែរ បើតាមដូចថាមានចិត្តធម៌អីចឹងណាអូន ដូចថាគេមកសុំ ខ្ញុំអីចឹង ខ្ញុំវារៀងអាណិតចឹងទៅយកមកឲ្យក៏មានដែរ ដូចថាគ្នាវាអស់កម្លាំងខ្លាំងអីចឹង អា ហ្នឹងមកខុសម៉ោងពេលក៏មានដែរ ដូចថាអាហ្នឹងមានធម៌ដូចថាម៉ែគេម៉ែយើងអីឃ្លានដើប អីរូច ។

វណ្ណៈ ៖ បាទ! ចឹងដូចថាមីងឃើញអ្នកជម្ងឺឈឺច្រើនចឹង មានចចិត្តចង់ជួយដែរឬក៏យ៉ាងម៉េចកាល ហ្នឹង?

យឹម ៖ ចិត្តចង់ជួយតាមតែថ្នាំអីទាល់គេឲ្យមក បានយើងជួយកើត ព្រោះថាដូចថាគេកំណត់ឲ្យថា ព្រលឹមឡើងចឹងដើរចាក់ចឹង ដើរចែកថ្នាំគ្រាប់ចឹង ចែកម៉ាសារចឹងទៅ ដល់ម៉ោង ។

វណ្ណៈ ៖ ចាក់ៗទៅ?

យឹម ៖ ចាក់ទៀតទៅ សារ៉ូមអាដបទឹកក្រូចហ្នឹង អ្នកជម្ងឺណាត្រូវបន្តោកចឹង ដាក់បន្តោកចឹងទៅ ។

វណ្ណៈ ៖ សារ៉ូមភាគច្រើនគេខ្លះគេថាទឹកដូង ឬក៏បើតាមមីងដឹង ឬក៏ស្អីគេទៅ?

យឹម ៖ បើតាមខ្ញុំដឹងគេចម្រោះយកទឹកស្រា យកចម្ហាយចឹងទេ ចម្ហាយខ្លាំងណា យកចម្ហាយ ព្រោះគេដាក់ថ្នាំខ្មែរអីចឹងហើយ ដាក់យកសម្រក់ទឹកចម្ហាយហ្នឹងមកដាក់ដបទៅ ។

វណ្ណៈ ៖ ចឹងប្រហែលជាមានពេលខ្លះទេ ទឹកដូងហ្នឹង?

យឹម : ហ្នឹងហើយទឹកដូងពេលខ្លះទេ ព្រោះយកមកចាក់តែទឹកដូងសុទ្ធក៏មិនកើតដែរ ព្រោះដាក់សារ៉ូមហ្នឹងដាក់ម៉េចកើតសុទ្ធ ។

វណ្ណៈ : បាទ! ខ្ញុំជួបពេទ្យដែរពេទ្យថាទឹកដូងហ្នឹងមានពេលខ្លះ ប៉ុន្តែទឹកដូងហ្នឹងអត់ទម្លាក់ទេ ។

យឹម : ហ្នឹងហើយ! គេថ្នម ។

វណ្ណៈ : គេចងអត់ឲ្យធ្លាក់ដល់ដីទេ ។

យឹម : ចាំ! ប៉ុនខ្ញុំមិនដែលជួបប្រទះអារឿងទឹកដូងទឹកអីមិនដឹងទេ ប៉ុនអាកន្លែងធ្វើក៏មិនអាចដឹងគេធ្វើពីគ្រឿងអីដែរណាអូន ។

វណ្ណៈ : គេឲ្យចាក់យើងចាក់ទៅ?

យឹម : គេឲ្យចាក់យើងដឹងតែចាក់ ។

វណ្ណៈ : ចឹងពេទ្យហ្នឹងមានពេទ្យឆ្មប ចំណេះទូទៅ ខាងធ្វើថ្នាំ?

យឹម : ធ្វើថ្នាំ ខាងគេផ្នែកស្ងួថ្នាំស្ងួដោយខ្លួន ឆ្មបៗដោយខ្លួន ព្យាបាលៗដោយខ្លួនចឹងទៅ តាមផ្នែកវា ។

វណ្ណៈ : ចុះពេទ្យទូទៅ ទូទៅដូចមីងទូទៅណ៎ា?

យឹម : ទូទៅហ្នឹងហើយ ។

វណ្ណៈ : ពេទ្យស្ងួថ្នាំចឹងដាច់ៗៗពីគ្នា?

យឹម : ចាំ! ស្ងួថ្នាំដោយខ្លួន ។

វណ្ណៈ : ចឹងដូចថាមីងចេះវាស់ ចេះចាក់ ចេះឲ្យថ្នាំទៅដល់អ្នកជម្ងឺ មីងចេះទាំងអស់ហ្នឹងហ៎?

យឹម : ខ្ញុំចេះមើលឈាមហើយវាស់កម្តៅវាស់អី អាទែម៉ែត្រវាស់កម្តៅហើយនិងចាក់ ចេះតែប៉ុណ្ណឹង ខ្ញុំគ្មានជ្រៅជ្រះអី មានទៅរៀនទៅអីផង ។

វណ្ណៈ : បាទ! បើតាមមីងគិតថាអ្នកជម្ងឺដែល រយៈពេល៣ឆ្នាំហ្នឹងមានស្លាប់ច្រើនទេមីង?

យឹម : ស្លាប់ច្រើនតើ ដូចថាក្មេងអាគ្មាអស់ជីវជាតិ ពួកមកពីកងចល័តកងអី ខែអាកញ្ជ្រិលហ្នឹងច្រើនណាស់ ។

វណ្ណៈ : អូមានកញ្ជ្រិលទៀត?

យឹម : ពេលកញ្ជ្រិលមកពីកងចល័ត មិនទាន់ជាគេឲ្យទៅវិញទៅអីវាលាប់ណាអូន ដល់ធ្វើការចឹងទៅវាស្លាប់ច្រើនណាក្មេង ជំនាន់ហ្នឹងកើតកញ្ជ្រិលច្រើនណាស់ ខ្លះចេញតាមភ្នែកតាមអីចឹងខ្វាក់ ខ្វាក់ភ្នែកខ្វាក់អីចឹងទៅ អស់ច្រើនណាស់រឿងនេះហ្នឹង វាខាតច្រើនក្មេង ជម្ងឺហ្នឹង

វាលាប់ណាហើយមិនទាន់ទេគេឲ្យទៅធ្វើការហើយក្មេង សែនដីសែនអីហ្នឹងវាលាប់ទៅដល់ យកមកវិញខ្ញុំមើលអត់ជាទេហ្នង ។

វណ្ណៈ : តែលាប់មើលអត់ជាហ្នង?

យឹម : ហ្នឹងហើយអត់ជា ស្លាប់ចឹងទៅក្មេងស្លាប់ច្រើន ។

វណ្ណៈ : ចឹងបើតាមមីងនៅហ្នឹងមីងដឹងថា អ្នកជម្ងឺប្រភេទច្រើនមនុស្សចាស់ ឬក៏ក្មេងច្រើនជាង?

យឹម : វាចំរុះដែរហ្នឹង បើចាស់វាចាស់ច្រើនហើម ទាល់តែជម្ងឺត្រូវវះត្រូវអីអត់សូវមានទេជំនាន់ហ្នឹង ត្រូវដូចថាវះកាត់ធំៗវាដូចអត់មានដូចឥលូវ ។

វណ្ណៈ : ពេទ្យវះកាត់ក៏មានដែរ?

យឹម : មានៗ ប៉ុន្តែអាជម្ងឺហ្នឹងវាមិនអាចបញ្ជូនទៅវះកាត់បាន គ្មាន! មានតែទៅហើមហត់ខ្វះជាតិវីតាមីន ដូចមិនមានប្លែកៗដូចឥលូវ បើប្លែកដូចឥលូវវាងាប់ច្រើនហើយ ព្រោះអត់មានពេទ្យសង្គ្រោះខ្លាំងដូចឥលូវណា៎ វាអត់មានត្រូវវះកាត់អី វះកាត់តាកែវតាអីវាមិនដឹងទេនៅខេត្ត ប៉ុនខ្ញុំដឹងតែត្រឹមស្រុកហ្នឹងចឹងណាអូន ។

វណ្ណៈ : ពេទ្យស្រុកហ្នឹងដែលគេបញ្ជូនមកតាមឃុំ មកមើលពេទ្យឃុំ មកមើលពេទ្យភូមិ អីរបៀបម៉េចអីដែលឃើញគេឲ្យដែរមកទេ?

យឹម : គេដូចថា មានឲ្យចុះមកមើលអ្នកជម្ងឺកន្លែងណាគ្រុនចាញ់ច្រើនអី គេហាមទៅដែរហ្នឹងណាឡានគេចុះមកមើលតាមភូមិចឹងដែរហ្នឹងណា៎ ទៅមើលកន្លែងគេមន្ទីរពេទ្យឃុំចឹងណា៎ គេឲ្យយើងទៅមើល ។

វណ្ណៈ : ជំនាន់ហ្នឹងចុះដល់មូលដ្ឋានអត់?

យឹម : ចា៎! មូលដ្ឋានទៅតាមភូមិ តាមឃុំនៅពេទ្យនៅដេកពេទ្យហ្នឹង ខ្ញុំនៅទៅត្រឹមហ្នឹង កន្លែងណាមានជម្ងឺធ្ងន់ៗអីហ្នឹង ។

វណ្ណៈ : នៅក្នុងសម័យហ្នឹងមីងអត់ដែរឃើញគេចងមនុស្សចងអីទេ នៅក្នុងពេទ្យហ្នឹង?

យឹម : ទេ! អត់ដែលប្រទះទេ ប៉ុនគ្រាន់ឮមានវាមិនអត់ទេហ្នឹងហើយ គេចងទាំងខ្សែៗយកទៅសម្លាប់ហ្នឹងមានតើអូន ប៉ុនពួកខ្ញុំដូចថាទៅនៅកន្លែងណាវាមិនអាចចេញទៅដឹងទេណា៎ គ្រាន់ថាឮមានហ្នឹងមានវាមិនអត់ទេវាសម្លាប់ហ្នឹងវាសម្លាប់ច្រើនណាស់ ប៉ុនយើងខាងចឹងគេម៉េចឲ្យដើរដឹង ហើយវាមិនដែលឃើញផ្ទាល់ភ្នែកទេអារឿងសម្លាប់ វាសម្លាប់១រយភាគរយហើយចងខ្សែយកទៅសម្លាប់ ស្លាបសេកហ្នឹងតែយើងមិនដែលប្រទះនៅភ្នែកទេ ប៉ុនអារឿងសម្លាប់ហ្នឹងសម្លាប់ច្រើនណាស់ ។

វណ្ណៈ : ចុះដូចជាយាយគេនយាយអីមិញហ្នឹងណា យាយគេនអីហ្នឹងគាត់ធ្វើពេទ្យហ្នឹងគាត់កាច អត់ ?

យឹម : គាត់នៅជាមួយពួកខ្ញុំហ្នឹង គាត់អត់សូវដែលអីដែរ ។

វណ្ណៈ : អត់អីទេណ៎?

យឹម : ចា៎! តាមធម្មតាតាមអីហ្នឹង គាត់មិនដែលស្តីដែរអីគាត់សម្តីតិចដែរណា គ្រាន់ថាគ្រាន់តែអប់រំយើងហ្នឹង គាត់មិនសូវចេះអីដែរហ្នឹង គាត់មិនចុះដើរព្យាបាលអីដូចជម្ងឺធ្ងន់អី គ្រាន់ថាទៅអើតមើលយើងដាក់សារ៉ូមដាក់អីចឹងទៅ ។

វណ្ណៈ : ចុះឧបមាថា មីងទៅមើលម្នាក់ហ្នឹងអ្នកជម្ងឺឈ្មោះក បើមើលអត់ជាតើគេយកពិន័យមីងទេ?

យឹម : អត់ទេ គេអត់ដែរទៅថាអញ្ចេះអញ្ចុះដែរ ព្រោះអត់បញ្ជូនទៅផងមើលទៅបើស្លាប់បើអីគេមិនបន្ទោសទេប៉ុនថាបើយើងនៅនេះនៅមើលចឹង ក្រែងលោជិតស្លាប់ជិតអីយើងប្រាប់គេដែរ ថាជម្ងឺហ្នឹងវាធ្ងន់ក្រែងលោឆ្លងមិនរួចមិនអីចឹងណាអូន ក៏គេមិន ។

វណ្ណៈ : ហ្នឹងគេអាចដឹងដែរ?

យឹម : ហ្នឹងដឹង! ក៏គេមិនថាឥលូវត្រូវបញ្ជូនត្រូវអី គេមិនបញ្ជូននៅស្លាប់ត្រឹមហ្នឹងចឹងទៅ ។

វណ្ណៈ : បាទ! កាលហ្នឹងមានឡានពេទ្យឡានអីដែរ?

យឹម : ឡានមិនសូវមានផងហ្នឹង ឡានម៉ូតូអីមិនសូវមានដឹកមានអី ទាល់គេអ្នកធំថៅហ្វាយស្រុកថៅហ្វាយខេត្តអីបានមានឡានជិះ នៅក្នុងពេទ្យប្រចាំការហ្នឹងគ្មានឡានទេ នៅកន្លែងពេទ្យស្រុកខ្ញុំហ្នឹងណា ។

វណ្ណៈ : ពេទ្យស្រុកគ្មានឡានទេ?

យឹម : គ្មានឡានទេ គ្មានដែលដឹកទៅថាធ្ងន់ដឹកថយទៅនេះទៅនោះអីអត់មានផង ។

វណ្ណៈ : គ្មានឡានពេទ្យសម្រាប់ដឹកអ្នកជម្ងឺទេ ។

យឹម : អត់មានទេ!

វណ្ណៈ : ចុះមីង ដល់ពេលណាមីងរៀបការជាមួយពូនៅឆ្នាំណា មានចាំទេ?

យឹម : មុនរដ្ឋហ្នឹងប្រហែល៥-៦ខែ ប្តេជ្ញាហ្នឹងមុនរដ្ឋដែលឡើងបែក នែ៎នេះណា ។

វណ្ណៈ : អញ្ចឹងឆ្នាំ៧៨?

យឹម : ហ្នឹងហើយមុន៧៩ហ្នឹង បែកគ្នាប៉ុន្មានខែហ្នឹង រៀបចំហើយប៉ុន្មានខែហ្នឹងបែកគ្នា ។

វណ្ណៈ : រៀបការហ្នឹងមីងស្ម័គ្រចិត្ត?

យឹម ៖ ចុះគេឲ្យហើយ ឲ្យទៅមិនស្គាល់គ្នាផង ។

វណ្ណៈ ៖ អញ្ចឹង?

យឹម ៖ ខ្ញុំ២គូហ្នឹងអត់ស្គាល់ ។

វណ្ណៈ ៖ រៀបការតាមអង្គការ?

យឹម ៖ តាមអង្គការ ។

វណ្ណៈ ៖ ចុះបើសិនជាមីងអត់បានស្គាល់បានដឹងមុន ឧបមាថាឧទាហរណ៍ថាស្រាប់គេយកមនុស្សពិការពិអីមកចឹងមីងព្រមការអត់ចឹង?

យឹម ៖ បើអ្នកអន្តត់ដៃអន្តត់ជើងម៉េច យើងប្រកែកមិនដឹងគេធ្វើម៉េចព្រោះយើងថាប្រកែកយើងថាមិនយកបើចឹងយកធ្វើម៉េចបើមនុស្សពិការ ហ្នឹងបើយើងប្រកែកមិនដឹងទេ ប៉ុនចិត្តយើងថាប្រកែកហើយណាំអូន បើសិនអញ្ចឹងណាំ ។

វណ្ណៈ ៖ បាទ!

យឹម ៖ អ្នកណាទៅយកធ្វើអី បើមនុស្សគេពិការ ប្រកែកដឹងគេព្រមឲ្យយើងឬមិនព្រម ប៉ុនយើងមិនជួបប្រកែកអ្នកពិការទេ ដោយសារអាថ្ងៃហ្នឹងហៅទៅហ្នឹង២គូរហ្នឹងឲ្យនិយាយថាឥលូវព្រមឬមិនព្រមអីចឹងទៅ គេហើយឥលូវយើងថាម៉េចបើគេថាចឹងហើយយើងសុខចិត្តថាយើងប្ដេជ្ញាថាយកចឹងទៅ ។

វណ្ណៈ ៖ ចឹងឧបមាថាមីងការហ្នឹងគេមានធ្វើពិធីជប់លៀងអីទេ?

យឹម ៖ មានជប់លៀងអីគ្រាន់តែ គណៈចៅហ្វាយស្រុកយើងមកប្រាប់យើងចឹងណាំ ។

វណ្ណៈ ៖ មានតាទិត មានយាយគេនអីចូលរួមដែរ?

យឹម ៖ ចាំ! ចូលរួមចៅហ្វាយស្រុកគេចូលរួម២គូរដែរ គ្រាន់ថាឥលូវគេប្ដេជ្ញាឲ្យយកជាគ្នាទៅអនាគតអីចឹងទៅ កុំឲ្យលែងលះគ្នាអីចឹង តែអ្នកមិនត្រូវគេយកទោសយើងទៀត បើសិនជាគេរៀបហើយ យើងមិនយកមិនត្រូវគ្នា គេដឹងរាយការណ៍ទៅគេយកទោសយើងទោះអាក្រក់ល្អសខ្មៅអីក៏នៅតែយកដែរ មានកម្មវិធីអីគ្មានដាក់អីទេ គ្រាន់តែនិយាយម៉ាម៉ាត់ពីរហើយបែកគ្នាទៅ ។

វណ្ណៈ ៖ បាទ! ចុះពូទៅធ្វើការផ្សេង?

យឹម ៖ ទៅគាត់ទៅធ្វើការនៅកងចល័តចឹងគាត់ទៅៗ ខ្ញុំនៅពេទ្យហ្នឹងចឹងគឺនៅទៅ ថ្ងៃ១០ថ្ងៃ២០គេចឹងទៅ គេមានកន្លែងគេឲ្យទៅជួបគ្នាចឹងទៅ ។

វណ្ណៈ ៖ ហ្អាក! មានកំណត់ថ្ងៃ១០ថ្ងៃ២០ទៀត?

យឺម ៖ ពេទ្យគេនេះ គេអ្នកនេះចឹងគិតថ្ងៃ១០ ថ្ងៃ១០ចឹងដូចថា ។

វណ្ណៈ ៖ ក្នុង១ខែចឹង មានដល់ថ្ងៃ១០?

យឺម ៖ ថ្ងៃ១០ហ្នឹង ថ្ងៃ១០ហ្នឹងដូចថាយើងអ្នកមានគ្រួសារចឹង គេអាចឲ្យទៅជួបគ្នា ឲ្យខាងប្រុសហ្នឹងទៅជួបគ្នាចឹងណាអូន ។

វណ្ណៈ ៖ ក្នុង១ខែម្ដង?

យឺម ៖ ១ខែ៣ដង ១០ថ្ងៃចឹង ហើយតែយើងទៅខុសថ្ងៃខុសនេះចឹង គេស្ដីអត់បាន ប៉ុនយើងមិនទៅក៏បានតែគេកំនត់ឲ្យចឹង ។

វណ្ណៈ ៖ កំណត់ឲ្យ១០ថ្ងៃជួបគ្នាម្ដង?

យឺម ៖ ចាំ!

វណ្ណៈ ៖ អោយតែដល់ថ្ងៃ១០?

យឺម ៖ ថ្ងៃ១០ហ្នឹង បើយើងរវល់អត់អីទេមិនមកក៏បាន ប៉ុនថាគេមិនឲ្យយើងមានគាតភាពអព្ចេះអព្ចុះអីចឹង ។

វណ្ណៈ ៖ បាទ ដល់ពេលចឹងពូមកជួបចឹងព្រលឹមឡើងចេញទៅវិញទៅ?

យឺម ៖ ទៅតាមកន្លែងយើងធ្វើការ ។

វណ្ណៈ ៖ ចឹងពូមកដល់ពេទ្យ មកដល់កន្លែងពេទ្យ?

យឺម ៖ មកកន្លែងពេទ្យ ។

វណ្ណៈ ៖ កន្លែងពេទ្យចឹងមានកន្លែងបន្ទប់ផ្សេងៗគ្នា?

យឺម ៖ ចា មានតើកន្លែងពេទ្យគេនៅលើចឹងទៅ អ្នកជម្ងឺនៅកន្លែងហ្នឹង ខ្ញុំកាលនៅគិរីហ្នឹងកាលនេះឥលូវគេទើបតែធ្វើនេះហ្នឹង កាលនេះអត់មានជាន់លើទេ ផ្ទះល្វែងគេពីដើមមកហើយមានជាន់លើចឹងទៅ អ្នកជម្ងឺនៅជាន់ក្រោម ។

វណ្ណៈ ៖ ចុះឧបមាថាបុគ្គលិកពេទ្យនៅផ្នែកផ្សេងទៀត?

យឺម ៖ បុគ្គលិកពេទ្យមានបន្ទប់គេផ្សេងៗទៀត មានតើ មានកន្លែងពេទ្យដោយឡែកបន្ទប់ដាក់ថ្នាំហ្នឹងពេទ្យនៅដេកហ្នឹង ។

វណ្ណៈ ៖ បាទ! ហើយមាន អ្នកជម្ងឺដូចថានៅផ្សេង ពេទ្យនៅផ្សេង?

យឺម ៖ ចាំ!

វណ្ណៈ ៖ ហើយចឹងពេទ្យអ្នកអត់ទាន់មានគ្រួសារនៅផ្សេង?

យឺម ៖ នៅផ្សេងចាំ!

វណ្ណៈ : ដល់ពេលមីងគេឲ្យបន្ទប់មួយផ្សេង?

យឹម : បន្ទប់នៅលើ ដូចថាអានេះយើងមានគ្រួសារហើយចឹងណា ដល់ហើយយើងដេកជាមួយពេទ្យគ្នាយើងវិញដដែល ដូចថាមកចឹងទៅគេឲ្យយើងមានបន្ទប់មានអីចឹងដែរណា៎ ។

វណ្ណៈ : បាទ! តែដល់ពេលមីងធ្វើចឹង ដល់ពេលវៀតណាមវ៉ៃចូលមីងរត់ទៅខាងណាវិញ?

យឹម : រត់ឡើងលើ ចេះទៅនឹងគេទៅដល់ភ្នំក្រវាញ ។

វណ្ណៈ : ហើយមីងម៉េចក៏មិនរត់ចូលផ្ទះ?

យឹម : ខ្ញុំរត់ចូលផ្ទះអី បែកគ្នាជាមួយប្ដីក៏មិនបានជួបគ្នាដែរ ខ្ញុំរត់ទៅតាមម៉ែឪ ។

វណ្ណៈ : ហ្អាក! ម៉ែឪរត់ដែរ?

យឹម : ម៉ែឪនេះ នៅភូមិហ្នឹងរត់ទៅភ្នំក្រវាញច្រើនណាស់ ទៅតាមផ្ទះអ៊ីខ្ញុំនេះនៅនឹងត្បូងនេះក៏ឡើងទៅដល់ភ្នំក្រវាញដែរ វាចេះតែម្ហូក(ប្រឡាច)គ្នា ដល់ម្ហូកហើយចេះតែឡើងៗចឹងទៅឡើងទៅដល់ភ្នំក្រវាញដល់វៀតណាមមកនេះ ដល់ជិតថៃហើយខ្ញុំ ព្នុសូរឡានថៃហើយហ្នឹងម្ហូកចឹងដល់នេះ ចុះមកវិញបានចុះមកវិញហើយ សឹងងាប់ដើរមិនចង់មកផ្ទះដងហ្នឹង ស្គមឡើងទៅឆ្ងាយ ។

វណ្ណៈ : ចុះពេលដែលមីងចុះទៅរត់ទៅដល់ទល់ដែនថៃហើយហ្នឹង តើជួបឧបសគ្គអីខ្លះមនុស្សស្លាប់តាមផ្លូវ?

យឹម : អូ! មនុស្សស្លាប់តាមផ្លូវអ្នកសែងអស់ជើងអស់អីនោះចោលអាគាត់អាទាវចឹងអីតាម ផ្លូវ យើងទៅក្រោយគេអ្នកគេទៅមុនហ្នឹង ងាប់អស់ហើយខ្ញុំទៅក្រោយចឹងទៅអ្នកនេះគេជម្លៀសទៅមុន ។

វណ្ណៈ : ហើយឆ្នាំណាមីងត្រឡប់ចូលភូមិវិញទៅ?

យឹម : ពី៧៩ហ្នឹងមកហ្នង ចុះមកហ្នង ។

វណ្ណៈ : ចុះមក ហើយជួបពូតាមផ្លូវដែរ?

យឹម : ពូហ្នឹង ខ្ញុំមកហ្នឹងមកនៅនេះ ខ្ញុំចុះទៅនៅផ្ទះឯត្រពាំងវន្ទនោះ ដល់នេះបានជួបជុំគ្នា ខ្ញុំមកនៅស្រុកគាត់នេះមក ។

វណ្ណៈ : ចុះពេលចុះមក មកដល់៧៩មកដល់ក្នុងភូមិក្នុងអីវិញចឹង តើមីងមានដឹងថានៅស្រុកគិរីវង្សយើងមានគេគាស់ឆ្អឹងសាកសពដូចថា អ្នកដែលស្លាប់ទៅដោយសារខ្មែរក្រហមសម្លាប់ចោលណា មីងមានបានដឹងទេគេគាស់ទៅដាក់វត្តណា កន្លែងណាខ្លះ?

យឹម ៖ គ្មានគាស់ទេសព សពនៅនេះហ្នឹងនៅកន្លែងស្លាប់ហ្នឹងគេឆាយលុបអស់រលីងហើយ គ្មានគាស់យកឆ្អឹងផងនៅកន្លែងមន្ទីរឃុំយើងហ្នឹង ឃុំកំពែងយើងហ្នឹងកាលនេះសុទ្ធតែជាផ្នូរជំនាន់ហ្នឹងកងទ័ពស្លាប់ៗគេយកមកចោលនៅហ្នឹង ដល់ពេលជំនាន់ឥលូវគេអត់ឲ្យមានផ្នូរផងហ្នឹងឆាយស្មើហើយអស់ មានណាទៅគាស់បាន គាស់ឆ្អឹងកូនឆ្អឹងចៅអីផងហ្នឹង ។

វណ្ណៈ ៖ បាទ! ប៉ុន្តែអញ្ចេះ ចង់និយាយថានៅក្នុងស្រុកគិរីវង្ស មានកន្លែងគេសម្លាប់មន្ទីរសន្តិសុខអីណា ក្រោយមកគេកាយដាក់វត្តដាក់អី មីងមានបានដឹងទេ?

យឹម ៖ គ្មានបានកប់ទេ ដឹងដូចទ័ពអីវាងាប់វាអីចឹងដឹកដូច ដឹកទៅកន្លែងវិមានសព គេហៅវិមានសពណា ។

វណ្ណៈ ៖ អាហ្នឹងឆ្នាំណា?

យឹម ៖ វិមានសពហ្នឹង មុន៧៩ហ្នឹងវាស្លាប់វៃគ្នាទៅស្រុកយួនហ្នឹង ។

វណ្ណៈ ៖ អាហ្នឹងគេហៅទ័ពទេ កងទ័ពទេ ។

យឹម ៖ ពួកទ័ពងាប់ច្រើនចឹងហើយបើប្រជាជន កប់តាមភូមិតាមអីចឹងទៅ តាមប្រឡាយអីចឹងទៅ តែទ័ពទេយកទៅដាក់កន្លែងវិមានសពហ្នឹងបានដាក់បាន ហ្នឹងគេដាក់កន្លែងដាក់ទ័ពចឹងបាន ។

វណ្ណៈ ៖ ចឹងប៉ុន្តែកន្លែងពេទ្យស្រុកពេទ្យហ្នឹងអត់មានកន្លែងព្យាបាលអ្នកជម្ងឺ ពួកទ័ពពួកអីចឹងទេ?

យឹម ៖ អត់ៗមានផង អត់មានព្យា ព្យាបាលតែប្រជាជនទេ ។

វណ្ណៈ ៖ ព្យាបាលតែប្រជាជនហ្នង?

យឹម ៖ ចា! ព្យាបាលប្រជាជនទ័ពគេដោយខ្លួន ទ័ពគេមានពីនោះមកអាណាមិនដាស្លាប់អី គេយកទៅទុកនៅនោះ ខ្ញុំបានមើលតែប្រជាជន ។

វណ្ណៈ ៖ បាទ!

យឹម ៖ អន្លុយលេងមកអូន!

វណ្ណៈ ៖ ចុះមីងអីដូចថានៅក្នុងភូមិហ្នឹង ក្រោយមកមានការគាស់ឆ្អឹងដាក់នៅឯវត្តឯអីមីងមានបានដឹងទេ?

យឹម ៖ មានបានគាស់ គ្មានដែលទៅគាស់ទេនៅកន្លែងហ្នឹងឃុំនៅហ្នឹង ចា៎! ឃុំនៅដល់ពេលគេឆាយគេអីទៅគ្មានទៅបានយកឆ្អឹងយកអីផង ។

វណ្ណៈ ៖ បាទៗ! ចុះមីងដោយសារជិតចប់ហើយ ខ្ញុំសម្ភាសមីងរឿងពេទ្យជិតចប់ហើយ ឥលូវខ្ញុំចង់សួរទាក់ទងនៅផ្នែកតុលាការវិញ សព្វថ្ងៃហ្នឹងមីងមានដឹងថាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេមីង?

យឹម ៖ មិនដឹងទេ! ពុតែវ៉ាដ្យូផ្សាយមិនដឹងកាត់ទោសអីណាផង អត់បានដឹងថាកាត់ទោសនៅកន្លែងណាខ្ញុំមិនដឹងទេពុតែផ្សាយដែរហ្នឹងណារឿងកាត់ទោសហ្នឹង ។

វណ្ណៈ ៖ អញ្ចឹង?

យឹម ៖ ចា៎!

វណ្ណៈ ៖ មីងអត់ដឹងថាមានពីណាខ្លះទេហ៎?

យឹម ៖ អត់ដឹង ពុតែវ៉ាដ្យូផ្សាយកាត់ទោសហ្នឹង នៅធ្វើស្រែនេះទាល់តែស្តាប់វ៉ាដ្យូដែរហ្នឹងណា ។

វណ្ណៈ ៖ មីងស្តាប់ទៅ មីងយល់យ៉ាងម៉េចដែរ?

យឹម ៖ កាត់ទៅវាត្រូវហើយព្រោះវាប្រល័យពូជសាសន៍ ចឹងទាល់យើងត្រូវកាត់ទោសចឹងហើយស្តាប់ទៅវាត្រូវរធ្វើចឹងហើយ សម្លាប់អស់មនុស្សវាច្រើន ។

វណ្ណៈ ៖ បាទ! អឺការកាត់ទោសហ្នឹងកាត់អ្នកដឹកនាំកំពូលធំៗដែរណា ជនដៃដល់ហើយថ្នាក់កំពូលមួយចំនួនដែរមីង ប៉ុន្តែរាល់ថ្ងៃគេចាប់ គេឃុំខ្លួនបណ្តោះអាសន្នតែ៥នាក់ទេ ហើយឌុចគេកាត់សេចក្តីហើយៗនៅតែចេញសាលក្រមប្រហែលថ្ងៃ២៦នេះ ខែហ្នឹងដែរណាមីងណា៎ មីងចាំស្តាប់តាមវ៉ាដ្យូថាគាត់ត្រូវដោះលែងឬជាប់គុកប៉ុន្មានឆ្នាំអីណា យើងដឹងពេលហ្នឹងហើយ នៅ៤នាក់ទៀតនៅតែ អៀងសារី ខៀវសំផន នួនជា អឺអៀងធិរិទ្ធ អីចឹងណាបាទ! គាត់ប្រហែលជាដើមឆ្នាំ២០១១ហ្នឹង ត្រូវកាត់ទោសគាត់ទៀតណា៎ ចឹងហើយបានជាថាទោះបីយើងមានវ័យចំណាស់ក៏ដោយប៉ុន្តែទោះបីជាយើងធ្វើខុសក្នុងជំនាន់ហ្នឹង ក៏យើងអត់រួចខ្លួនដែរ ត្រូវគេកាត់ទោសកាត់អីចឹងណាមីង ។ បាទ! ចុះមីងយល់ថាការកាត់ទោសហ្នឹង អឺថ្នាក់ដឹកនាំខ្មែរក្រហមហ្នឹង មីងគិតថាធ្វើចឹងត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេតាមយោបល់ របស់មីងវិញមីង?

យឹម ៖ តាមយោបល់មីងត្រឹមត្រូវ គឺវាសម្លាប់មនុស្សច្រើន ត្រូវកាត់ទោសចឹង ។

វណ្ណៈ ៖ ចុះមីងរាល់ការងារទាំងអស់ហ្នឹងទាំងថ្នាក់លើ ទាំងថ្នាក់ក្រោមអី មីងគិតថាថ្នាក់ក្រោមដូចតាមមូលដ្ឋានអីហ្នឹងទាំងអស់ មីងថាគេទទួលបញ្ជា ឬក៏ផែនការថ្នាក់លើមកដែរ ឬក៏យើងចេះតែធ្វើដោយខ្លួនឯងទេ អ្នកថ្នាក់ក្រោមថ្នាក់អីមូលដ្ឋានអីហ្នឹងណា?

យឹម ៖ សព្វថ្ងៃ រាល់ថ្ងៃអីហ្នឹង?

វណ្ណៈ ៖ អត់ទេ! ជំនាន់ប៉ុលពតណា ។

យឹម ៖ ជំនាន់ប៉ុលពតហ៎ នៅតាមភូមិតាមអីគេមានប្រធានភូមិប្រធានឃុំគេ ចឹងទៅគេធ្វើតាមថ្នាក់របស់គេចឹង ។

វណ្ណៈ : ចុះបើនៅកន្លែងមីង កន្លែងមីងៗពេទ្យចឹងមីងទទួលបញ្ញាពីថ្នាក់មេមកដែរ?

យឹម : ហ្នឹងហើយ!

វណ្ណៈ : ហើយមេហ្នឹងអាច ហើយមីងគិតថាមេអាចទទួលបញ្ញាពីថ្នាក់លើមកទៀត?

យឹម : ពីថ្នាក់លើបន្តគ្នាអូន ។

វណ្ណៈ : ចឹងមីងគិតថាចឹងហ៎?

យឹម : ហ្នឹង គេបន្តពីលើមកខ្ញុំអាចដឹងតែត្រឹមគេយកមកឲ្យចឹង ហើយព្យាបាលចឹងទៅ ។

វណ្ណៈ : បាទ! ចឹងមីងអឺ ដូចជាមីងគិតថាតុលាការមានសារៈសំខាន់ទេ?

យឹម : សំខាន់ៗកាត់ទោសចឹងត្រូវហើយ ។

វណ្ណៈ : បាទ! ចុះពេលតុលាការហ្នឹងអាចមានផលប្រយោជន៍អីសម្រាប់ប្រជាជនយើងប្រជាជនខ្មែរទូទៅណា៎?

យឹម : មានផលប្រយោជន៍ដល់ប្រជាជនហើយព្រោះកាត់ទោសឲ្យអ្នកវាប្រល័យពូជសាសន៍ហ្នឹង ។

វណ្ណៈ : ចឹងមីងមានអ៊ីដែលចង់និយាយទៀតទេ ខ្ញុំដូចអស់សំនួរសួរមីងហើយ?

យឹម : ខ្ញុំអស់ហើយអត់មានអីផងអូន ។

វណ្ណៈ : បាទ ចឹងខ្ញុំអរគុណមីងច្រើនហើយណា៎!

យឹម : ចា៎!

**ចប់**